មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក

ខែមិនា ឆ្នាំ២០១៣

# កំណែទម្រង់ដីធ្លី

## មូលន័យសង្ខេប

កំណត់ត្រាសង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅ និងការវិភាគពីសភាពការណ៍នៃប្រវត្តិសាស្ត្រនាពេលថ្មីៗនេះរបស់ព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ដែលបានធ្វើឲ្យប៉ះពាល់មិនល្អដល់ការវិវឌ្ឍន៍នៃកម្មសិទ្ធិ និងការចុះបញ្ជីដីធ្លី; ពិភាក្សាពីបុព្វហេតុនៃរចនាសម្ព័ន្ធ ផ្នែកគតិយុត្ត និងសង្គមដែលនៅពីក្រោយការដកហូតដីធ្លី និងពីរបៀបដែលរាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") ខកខានពុំបានការពារសិទ្ធិមនុស្ស ព្រមទាំងបានរំលោភបំពានសិទ្ធិទាំងនោះដោយសកម្មតាមរយៈអំពើហិង្សា និងការគាបសង្កត់; ហើយនិងផ្តល់នូវអនុសាសន៍មួយចំនួនដែលមានគោលបំណងដោះស្រាយនូវបញ្ហាទាំងនេះ។

ការលុបបំបាត់កម្មសិទ្ធិដីធ្លីដោយរដ្ឋាភិបាលនៅក្នុងរបបខ្មែរក្រហម បានឈានទៅដល់ការបំផ្លាញចោលនូវឯកសារបញ្ជាក់ពីកម្មសិទ្ធិដីធ្លីជាច្រើន និងបានបង្កើតដំណាក់កាលសម្រាប់ធ្វើការបង្ហាញនូវច្បាប់នានាជាលំដាប់ៗដែលបានស្តារឡើងវិញនូវសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាចំពោះកម្មសិទ្ធិដីធ្លី។ ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះផ្តល់នូវទស្សនៈទានជាទូទៅនៃកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា។ ផ្នែកពីរនៃកំណត់ត្រាសង្ខេបពិភាក្សាអំពីបុព្វហេតុសំខាន់នៃជម្លោះដីធ្លី និងការដកហូតដីធ្លី នៅក្នុងប្រទេសកម្ពុជា ដោយរួមមាន៖ ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ("ដី.ស.ស") ដ៏ច្រើនសន្ធឹកសន្ធាប់ ប្រព័ន្ធច្បាប់គ្រប់គ្រងសិទ្ធិដីធ្លីមានភាពសាំញ៉ាំ និងកង្វះទំនាក់ទំនងឲ្យបានគ្រប់គ្រាន់ពីសំណាក់ រ.រ.ក អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ចន្លោះប្រហោងក្នុងការវាស់វែងដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិព្រមទាំងការបំភិតបំភ័យទៅលើប្រជាពលរដ្ឋដោយបុគ្គលមានអំណាច និងមានទំនាក់ទំនងជាមួយនឹងអ្នកមានអំណាច។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ម.ស.ម.ក ផ្តល់នូវអនុសាសន៍មួយចំនួន ហើយក្នុងចំណោមអនុសាសន៍ទាំងនោះមានចំណុចគន្លឹះចំនួនបួនដូចខាងក្រោមនេះ៖

១. បន្តគោលនយោបាយផ្អាកជាបណ្តោះអាសន្នដែលកំពុងអនុវត្តលើការផ្តល់ដីសម្បទានសេដ្ឋកិច្ចបន្ថែមទៀតដើម្បីជាផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម និងធ្វើការសើរើឡើងវិញឲ្យបានគ្រប់ជ្រុងជ្រោយ និងមានតម្លាភាពទៅលើដីទាំងឡាយណាដែលបានផ្តល់សម្បទានរួចហើយ ដើម្បីកំណត់អំពីការអនុលោមតាមច្បាប់ ហើយនិងធ្វើការដកហូតយកមកវិញ ប្រសិនបើរកឃើញថាពុំបានអនុវត្តស្របតាមច្បាប់ទេនោះ។

២. បញ្ឈប់ជាបន្ទាន់នូវរាល់ការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំពីដីរបស់ពួកគេ និងដោះលែងភ្លាមពីការឃុំខ្លួន និងទម្លាក់ចោលនូវការចោទប្រកាន់ដែលកំពុងតែមានចំពោះអ្នកទាំងឡាយណា ដែលត្រូវបានអាជ្ញាធរបានចាប់ខ្លួនដោយសារតែធ្វើការតវ៉ាដោយអហិង្សាប្រឆាំងទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល។

៣. ផ្តល់ជូនប្រជាពលរដ្ឋជាបន្ទាន់នូវប័ណ្ណកម្មសិទ្ធិដីធ្លីជាបឋម ព្រមទាំងប្លង់រឹងនៅពេលបន្ទាប់មក ចំពោះប្រជាពលរដ្ឋទាំងឡាយណាដែលគួរត្រូវបានគេ*ចាត់ទុកថា* កំពុងកាន់កាប់ដីរបស់ពួកគេដោយស្របច្បាប់ លុះត្រាតែមានការបង្ហាញហេតុផលជាក់លាក់ មិនបង្ខិតបង្ខំ និងមានតម្លាភាពក្នុងការកំណត់ផ្សេងពីនេះ។

កំណត់ត្រាសង្ខេបនេះ គឺតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## សាវតារៈ ប្រវត្តដីធ្លីនៅកម្ពុជា

របត់នៃការផ្លាស់ប្តូរដ៏ទូលំទូលាយនៅក្នុងសង្គមកម្ពុជា ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយរឿងរ៉ាវថ្មីៗនេះ ធៀបជាមួយនឹងអតីតកាល ដែលរដ្ឋាភិបាលបង្កមហន្តរាយគ្រប់គ្រងដោយរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនត្រឹមតែធ្វើឲ្យមានការឈឺចាប់ និងការដកហូតសិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងរលើប្រជាពលរដ្ឋខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតដំណាក់កាលមួយដែលនាំឲ្យប្រជាពលរដ្ឋខ្លួនបាត់បង់នូវកម្មសិទ្ធិដីធ្លី ការប្រឹងប្រែងក្រោយមកទៀតរបស់ពួកគេដើម្បីឲ្យត្រឡប់ដូចដើមវិញ ហើយនិងការតស៊ូនាពេលថ្មីៗរបស់ប្រជាពលរដ្ឋ ដើម្បីការពារមិនឲ្យមានការដកហូតដីធ្លីពីសំណាក់រដ្ឋាភិបាល ដែលខកខានពុំបានទទួលស្គាល់ពីកាតព្វកិច្ចដែលរដ្ឋាភិបាលត្រូវបំពេញជូនដល់ពលរដ្ឋ។ នៅពេលរបបខ្មែរក្រហមបានឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ ពួកគេបានកម្ទេចចោលនូវប្រព័ន្ធដែលមានភាពស៊ីសង្វាក់ចំពោះកម្មសិទ្ធិដីធ្លីឯកជនដែលបានទទួលស្គាល់ដោយច្បាប់ និងការរក្សាគោលបញ្ជីដែលមានពីមុនមក ដែលបានលុបបំបាត់ចោលនូវកម្មសិទ្ធិដីធ្លី និងបំផ្លាញចោលនូវបញ្ជីបញ្ជាក់កម្មសិទ្ធិដីធ្លីស្ទើរទាំងស្រុង ព្រមទាំងធ្វើឲ្យប៉ះពាល់ជាខ្លាំង មិនត្រឹមតែទៅលើម្ចាស់ដែលមានដីឥឡូវនេះទេ ប៉ុន្តែក៏ប៉ះពាល់ពីរបៀបដែលដីត្រូវបានជាកម្មសិទ្ធិនាពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជា។

ករណីនេះបានបន្តមករហូតមិនត្រឹមតែដល់ឆ្នាំ១៩៩២[1] នៅពេលដែលច្បាប់ភូមិបាលថ្មីត្រូវបានបង្កើតឡើងដោយ រ.រ.ក ដែលជាថ្មីម្តងទៀតប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឲ្យមានកម្មសិទ្ធិដីឯកជន និងអាចធ្វើអនុប្បទានដីឯកជនបាន។ ការផ្លាស់ប្តូរដ៏ធំធេងនាពេលបន្ទាប់មក ដែលបានកើតឡើងតាមរយៈការអនុម័តនូវច្បាប់ភូមិបាលឆ្នាំ២០០១ ដែលមិនត្រឹមតែបានទទួលស្គាល់សិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់លើដីធ្លី និងធ្វើអនុប្បទានប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិដីធ្លី ដែលជាតម្រូវការចាំបាច់បំផុតនោះទៀតផង។[2] ច្បាប់ផ្សេងៗ បានបង្កើតឡើងជាបន្តបន្ទាប់ ចំណោមច្បាប់ទាំងនោះក៏មានអនុក្រឹត្យលេខ១៤៦ ដែលចេញកាលពីឆ្នាំ២០០៥ ដែលបានអនុញ្ញាតឲ្យរដ្ឋាភិបាលធ្វើការផ្តល់ ដី.ស.ស ដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម និងការអនុម័តក្រមរដ្ឋប្បវេណីកម្ពុជាក្នុងឆ្នាំ២០១១។[3] ការអនុវត្តច្បាប់ទាំងនេះ បានទទួលការរិះគន់ជាខ្លាំង ដោយសារតែច្បាប់នេះបានបម្រើផលប្រយោជន៍ឲ្យតែជនមានទ្រព្យធន និងជនដែលមានទំនាក់ទំនងស្និទ្ធនឹងអ្នកនយោបាយនៅក្នុងប្រទេសកម្ពុជា ជា

[1] ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ក្រឹត្យលេខ ០០១ (ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២(កាត់)

[2] ច្បាប់ភូមិបាលឆ្នាំ២០០១ នស/រកម/០៨០១/១៤(ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១(កាត់)មាត្រា១០

[3] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០(ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)(កាត់)

ជាងបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋខ្មែរដែលជាអ្នកទទួលផលប្រយោជន៍ពីច្បាប់ដែលត្រូវបានបង្កើតឡើងនោះ។

ក្នុងឆ្នាំ២០១១ មានការប៉ាន់ប្រមាណថា ប្រជាពលរដ្ឋខ្មែរចំនួន១៥០,០០០នាក់នៅទូទាំងប្រទេសបានរស់នៅប្រឈមនឹងការបណ្តេញចេញដោយបង្ខំនៅតាមបណ្តាសហគមន៍នានានៅទីជនបទ និងទីក្រុង[4] ដោយប្រជាពលរដ្ឋខ្មែរ និងជនជាតិដើមភាគតិចកំពុងតែត្រូវបានគេបដិសេធនូវសិទ្ធិទទួលបានលំនៅ សិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិប្រកបមុខរបរចិញ្ចឹមជីវិត។ ជាងនេះទៅទៀត យើងពិនិត្យឃើញថាជម្លោះដីធ្លីជាច្រើនកើតឡើងនៅតាមតំបន់ដែលមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចខ្លាំង ដូចជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់សោម ក៏ដូចជារាជធានីភ្នំពេញផងដែរ ដែលនេះពិតជាចំបាច់ណាស់ដែលថា សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា នឹងមិនត្រូវបានដោះដូរជាមួយនឹងការប្រើប្រាស់អំណាចហិរញ្ញវត្ថុ ពីសំណាក់ក្រុមជនមានអំណាចនៅក្នុងប្រទេសកម្ពុជានោះឡើយ។

បន្ថែមពីលើការ"ចាប់យកដីធ្លី"ដោយប៉ិនប្រសប់ពីក្រុមជនមានទ្រព្យធន និងជនដែលមានទំនាក់ទំនងជាមួយអ្នកនយោបាយនៅក្នុងសង្គមកម្ពុជា បរិយាកាសរបស់ប្រជាជនកម្ពុជា និងសុវត្ថិភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេគឺត្រូវគំរាមកំហែងដោយក្រុមអ្នកវិនិយោគិនបរទេសឱកាសនិយមមួយចំនួន ដែលផ្តោតជាសំខាន់លើការកេងប្រវ័ញ្ចផលប្រយោជន៍លើដីធ្លី និងធនធាននានារបស់ប្រទេស។ អ្នកវិនិយោគទាំងនេះ សម្លឹងឃើញនូវគោលនយោបាយរបស់ រ.រ.ក ថាមានដំណើរការក្នុងរយៈពេលខ្លី ដោយសារតែអស្ថិរភាពរបស់ រ.រ.ក ដែលគេប្រមើលឃើញ និងភាពមិនអាចទាយទុកជាមុនបានលើការប្រែប្រួលនូវគោលនយោបាយរបស់ រ.រ.ក ហើយហេតុដូច្នេះមានការលើកទឹកចិត្តតិចតួចដល់អ្នកវិនិយោគដើម្បីដាក់ការវិនិយោគទុនលើគម្រោងរយៈពេលយូរ ដែលមានគោលបំណងអភិវឌ្ឍន៍ជានិរន្តរភាព។

បញ្ហានានាដែលប្រជាពលរដ្ឋកម្ពុជាកំពុងតែប្រឈមមុខគឺ ការគ្មានសិទ្ធិអំណាចក្នុងការការពារដីធ្លីរបស់ពួកគេពីការរឹបអូសយកដោយខុសច្បាប់ ហើយជាចុងក្រោយនាំឲ្យបាត់បង់នូវមធ្យោបាយសម្រាប់ចិញ្ចឹមជីវិត និងការផ្គត់ផ្គង់ដល់ខ្លួនឯង និងក្រុមគ្រួសារ ហើយក៏បាត់បង់នូវការទទួលបានធនធានធម្មជាតិ ដូចជា ស្បៀងអាហារ និងទឹក ព្រមទាំងធនធានផ្នែកសង្គម មានដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងទីផ្សារ ហើយជាលទ្ធផលបាត់បង់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋកម្ពុជា ទទួលផលប៉ះពាល់បន្ថែមទៀត ដោយសារតែពាណិជ្ជភាវូនី–យកម្មរបស់ រ.រ.ក និងការប្រើប្រាស់ខុសទិសដៅនូវរាល់ធនធានធម្មជាតិដែលនៅជាប់នឹងដី រួមបញ្ចូលទាំងព្រៃឈើ បឹង ទន្លេ ដែលនាំឲ្យមានការប៉ះពាល់យ៉ាងដំណំជុំវិញបរិដ្ឋានរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា។

## មូលហេតុបណ្តាលឲ្យមានជម្លោះ និងការដកហូតដីធ្លី

ទោះបីមានការការពារត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា("រដ្ឋធម្មនុញ្ញ") និងបានបញ្ចូលក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិយ៉ាងណាក្តី ក៏ រ.រ.ក អនុញ្ញាតឲ្យមានការរឹបអូសយកដីធ្លី និងធនធាននានា ដោយពុំបានគោរពតាមដំណើរការត្រឹមត្រូវ និងស្របតាមក្របខណ្ឌច្បាប់ ទោះជាខ្លួនមានកាតព្វកិច្ចក្នុងការ

[4]សិទ្ធិលំនៅដ្ឋានចាំបាច់ត្រូវបង្ខំ 'ផលប៉ះពាល់សេដ្ឋកិច្ចនៃ សង្គមលើការបណ្តេញចេញដោយបង្ខំ នៅកម្រិតគ្រួសារ ក្នុងទីក្រុងភ្នំពេញ' (របាយការណ៍)(ឆ្នាំ២០១១)០៨ អាចរកបានតាម៖www.hrtfcambodia.org/files/SEI_of_Force_Eviction_Report_ENG.pdf

ទទួលខុសត្រូវចំពោះសុខមាលភាពរបស់ប្រជាពលរដ្ឋ។ បញ្ហានេះគឺដោយសារតែជាផ្នែកមួយនៃអំពើពុករលួយដែលរីករាលដាល និងវប្បធម៌និទណ្ឌភាពក្នុងជួរ រ.រ.ក។

**<u>ដីសម្បទានសេដ្ឋកិច្ច</u>**

ផ្ទៃដីដ៏ធំធេង បានត្រូវផ្ទេរឲ្យ និងនៅតែបន្តផ្ទេរពីសំណាក់ រ.រ.ក ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មក្នុងរូបភាពនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ("ដី.ស.ស") ដីសម្បទានសង្គមកិច្ច ("ដី.ស.ក") និងតំបន់សេដ្ឋកិច្ចពិសេស ("តំ.ស.ពិ") ដោយគ្មាន៖ (១) ការប្រកាន់ខ្ជាប់តាមការកម្រិតតាមផ្លូវច្បាប់អំពីទំហំដីដែលត្រូវផ្តល់ជូន (២) ការចាត់ចំណាត់ថ្នាក់ឲ្យបានត្រឹមត្រូវជាមុននូវដីដែលត្រូវទទួលបានដោយស្របច្បាប់ សម្រាប់ធ្វើការផ្ទេរទាំងបែបនោះ (៣) ការវាយតម្លៃជាបឋមដែលចាំបាច់អំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម និង (៤) ការគោរពដល់សិទ្ធិរបស់ប្រជាពលរដ្ឋដែលត្រូវទទួលបានការពិគ្រោះយោបល់ និងទទួលបានសំណងដោយយុត្តិធម៌។ ជាពិសេស បើទោះជាមានការកំណត់ពីការផ្តល់ទំហំ ដី.ស.ស មិនឲ្យច្រើន១០.០០០ហិកតា ឲ្យសម្រាប់កម្មសិទ្ធិករម្នាក់ៗ[5] ក្រុមហ៊ុនជាច្រើនដែលមានថៅកែតែមួយទទួលបានលើសពីទំហំដីកំណត់១០.០០០ហិកតា ដោយមិនអនុលោមតាម និងមិនត្រូវគេធ្វើឡើងឲ្យបានស្របទៅតាមតម្រូវការនេះ ឬក៏ការចុះឈ្មោះផ្សេងៗពីគ្នាឲ្យក្រុមហ៊ុនជាច្រើនរបស់ពួកគេ។

ដី.ស.ស ត្រូវបានប្រើប្រាស់ជាឧបករណ៍ដោយ រ.រ.ក ដើម្បីផ្ទេរទំហំផ្ទៃដីដ៏ធំធេង ពីប្រជាពលរដ្ឋកម្ពុជា ដើម្បីជាផលប្រយោជន៍ពាណិជ្ជកម្ម ហើយការផ្តល់ដីសម្បទាននោះ គឺជាការផ្តល់រង្វាន់ទៅឲ្យជនដែលមានទំនាក់ទំនងស្និទ្ធផ្នែកនយោបាយ ដែលជាការខាតបង់ដល់ប្រជាពលរដ្ឋកម្ពុជា។ ថ្វីត្បិតតែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាថាផ្អាកជាបណ្តោះអាសន្នក្នុងការផ្តល់ ដី.ស.ស ដែលបានចូលជាធរមានកាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ លុះត្រាតែ ដី.ស.ស ទាំងឡាយណាដែលស្ថិតក្នុងដំណើរការផ្តល់រួចហើយ ដី.ស.ស ជាច្រើននៅតែបន្តប្រគល់ទៅឲ្យក្រុមហ៊ុនដោយពុំមានការពន្យល់ពីហេតុផលណាខ្លះ ដែលក្រុមហ៊ុនទាំងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការអនុវត្តជាពិសេសនោះទេ។ ជាងនេះទៅទៀតនោះ លក្ខណៈវិនិច្ឆ័យដែលលោកនាយករដ្ឋមន្ត្រីបានសន្យាដែលគួរត្រូវបានប្រើក្នុងការពិនិត្យពិច័យទៅលើ ដី.ស.ស ទាំងឡាយណាដែលបានធ្វើសម្បទានរួចហើយដើម្បីកំណត់អំពីការអនុវត្តស្របជាមួយនឹងច្បាប់នោះនៅមិនទាន់ត្រូវបានគេបង្ហាញនៅឡើយទេ ដូច្នេះហើយគោលនយោបាយទាំងនេះខ្វះតម្លាភាពទាំងស្រុង។ ជាលទ្ធផល ប្រជាពលរដ្ឋកម្ពុជានៅតែត្រូវបានគេដកហូតដីធ្លីជាបន្តបន្ទាប់ ដោយពុំមានការស៊ើបអង្កេត ឬក៏សើរើមើលឲ្យបានត្រឹមត្រូវ។

ករណីថ្មីនេះៗ នៅក្នុងខេត្តស្ទឹងត្រែង អ្នកភូមិបានគេបញ្ជូនទៅកាន់កោះមួយដែលហ៊ុំព័ទ្ធដោយដី ដែលកាត់ផ្តាច់ទាំងស្រុងពីធនធានសម្រាប់ទ្រទ្រង់ជីវិតជាមូលដ្ឋាន ដែលពួកគេធ្លាប់តែអាស្រ័យមកកាលពីមុន។ ដោយឡោមព័ទ្ធទាំងស្រុងដោយ ដី.ស.ស ពីរកន្លែង ដែល រដ្ឋាភិបាលបានផ្តល់ទៅឲ្យក្រុមហ៊ុនវៀតណាម និងក្រុមហ៊ុនចិន ដែលជាការរឹតត្បិតមិនឲ្យអ្នកភូមិអាចស្វែងរកបាននូវអាហារ ទឹក និងផ្លូវថ្នល់ អាយុជីវិតរបស់ពួកគេត្រូវបានធ្លាក់ចុះទៅជាមានស្ថានភាពដូចអ្នកជាប់គុកនៅលើដីធ្លីរបស់ខ្លួនឯងយ៉ាងដូច្នោះ។[6]ការរឹតត្បិតនៃការទទួលបាននេះ

---

[5]អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច លេខ. ១៤៦ អនក/បក(ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥)(កាត់)

[6]កក្តិ ស៊ាងលី និង ប្រ៊ីហ្គេត ឌី ខើគុ 'ដាក់អ្នកភូមិឲ្យរស់នៅឯកការ ស្តមស្តាំង' ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២

គឺជាការរំលោភទាំងស្រុងទៅនឹងមាត្រា៥៨ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលចែងថា ដី.ស.ស *"មិនអាចប៉ះពាល់ផ្លូវគមនាគមន៍ដីចំណីផ្លូវ និងដីចាំបាច់សម្រាប់ថែទាំ ក៏ដូចជា ផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបម្រុង ដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ"។*[7] ដី.ស.ស ទាំងនេះពុំគួរណាត្រូវបានគេផ្តល់ទៅឲ្យក្រុមហ៊ុននោះទេ រ.រ.ក គួរគោរពដល់សិទ្ធិរបស់អ្នកភូមិដោយ គួរតែធ្វើការវាយតម្លៃពីផលប៉ះពាល់ដល់សង្គមជាមុនសិន។

## ច្បាប់មានលក្ខណៈស្មុគស្មាញ និងខ្វះការប្រាស្រ័យទាក់ទង

ជាប្រទេសមួយដែលត្រូវបានរាយការណ៍ដោយធនាគារពិភពលោកថា មានចំនួនប្រជាជននៅតាមជនបទរហូតទៅដល់៨០%[8] កាលពីឆ្នាំ២០១១ ហើយអាត្រាអក្ខរៈភាពយុវជននៅតាមជនបទមាន៧៧,៦%[9] តាមរបាយការណ៍ធ្វើឡើងក្នុងឆ្នាំ២០០៨ ប្រព័ន្ធគតិយុត្ត និងច្បាប់នានា ពិតជាលំបាកយល់នាំឲ្យអ្នកភូមិទាំងនោះភាគច្រើនដែលទំនងជាជនរងគ្រោះពីការរឹបអូសយកដីធ្លីដោយពុំត្រឹមត្រូវ។ រួមផ្សំបញ្ហានៃភាពសាំញ៉ាំផ្នែកច្បាប់នៅក្នុងប្រព័ន្ធគតិយុត្ត និងច្បាប់នានាផងនោះ រ.រ.ក ធ្វើតិចតួច ឬក៏មិនធ្វើសកម្មភាពអ្វីសោះក្នុងការប្រាស្រ័យទាក់ទងចំពោះគោលនយោបាយសំខាន់ៗពាក់ព័ន្ធទៅនឹងសិទ្ធិដីធ្លីទៅកាន់ប្រជាពលរដ្ឋរបស់ខ្លួន ព្រមទាំងជ្រៀតជ្រែកយ៉ាងសកម្មជាមួយនឹងតតិយជននៅក្នុងការប៉ុនប៉ងធ្វើដូច្នោះថែមទៀតផង ។

ឧទាហរណ៍ ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងពីដំណើរការសម្រាប់ចុះបញ្ជីលើដីធ្លីរួមរបស់សហគមន៍ជនជាតិដើមភាគតិច[10] ដែលមានអត្ថន័យក្នុងការការពារនូវដីធ្លីរបស់សហគមន៍ទាំងនេះ ក្នុងទម្រង់ជាប័ណ្ណកម្មសិទ្ធិលើដីសហគមន៍។ យ៉ាងណាក្តី ប័ណ្ណកម្មសិទ្ធិបែបនោះ មិនទាន់ត្រូវបានគេផ្តល់ជូននៅឡើយទេ ហើយប្រជាពលរដ្ឋជនជាតិដើមភាគតិច ដូចជាជនជាតិដើមភាគតិចដែលរស់នៅក្នុងខេត្តមណ្ឌលគិរីបានទទួលរងនៃការបំពានយកដី ការ ទន្ទ្រានយកដីជាទីកន្លែងគោរពសក្ការៈរបស់ពួកគេ ព្រមទាំងគំរាមដល់ការបាត់បង់នូវព្រៃឈើ និងវប្បធម៌របស់ពួកគេទៀតផង។ ការរំលោភបំពានសិទ្ធិកាន់កាប់ដីធ្លីនេះគឺត្រូវបានបង្ហាញឡើងលើទំហំផ្ទៃដីដ៏ធំសម្បើមតាមរយៈការ ផ្តល់សម្បទានដីចំនួនជិត ២០០.០០០ហិកតា ទៅឲ្យក្រុមហ៊ុនចិន[11] ឈ្មោះ វ៉ូ ហ្សីហ្សាន (អ៊ិល អេស គ្រុប) ដើម្បីអភិវឌ្ឍជាចំការដាំដើមស្រល់នៅលើដីពីបុរាណកាលរបស់ជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី ដែលនេះពិតជាផ្ទុយនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ដែលចែងថា ព្រំប្រទល់ដីរបស់ជនជាតិដើមភាគតិច ត្រូវបានធ្វើឡើង និងត្រូវបានទទួលស្គាល់ដោយច្បាប់ផងដែរ។

ខ្វះការប្រាស្រ័យទាក់ទងពីសំណាក់ រ.រ.ក ចំពោះច្បាប់ស្តីពីសិទ្ធិកាន់កាប់ដីធ្លី គឺធ្វើឲ្យរឹតតែធ្ងន់ធ្ងរ ដោយហេតុថាប្រជាពលរដ្ឋដែលភាគច្រើនទំនងជាប្រឈមនឹង ហានិភ័យនៃការបាត់បង់ដីធ្លីរបស់ខ្លួន គឺជាអ្នកដែលមានមធ្យោបាយតិចតួចណាស់ ដើម្បីតទល់នឹងការរំលោភបំពាននានា ដែលជាញឹកញាប់ពួកគេខ្វះការអប់រំ ខ្វះប្រាក់

---

[7]ច្បាប់ស្តីពីព្រៃឈើ ៈជំពូក៩ៈអ្នកប្រើសិទ្ធិបែបប្រពៃណី ការគ្រប់គ្រងលើព្រៃសហគមន៍ និងព្រៃឯកជន

[8]ធានាគារពិភពលោក ទិន្នន័យរបស់ធានាគារពិភពលោក(តួលេខត្រឹមត្រូវ កាលពីថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១២) អាចរកបានតាមៈ http://databank.worldbank.org

[9]ធានាគារពិភពលោក ទិន្នន័យរបស់ធានាគារពិភពលោក(តួលេខត្រឹមត្រូវ កាលពីថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១២) អាចរកបានតាមៈ http://databank.worldbank.org

[10]ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា២៣-២៨

[11]វត្តមានក្រុមហ៊ុនចិននៅកម្ពុជាមានការកើនឡើង

កាក់ និងខ្វះទំនាក់ទំនងខាងនយោបាយ ដែលជាប្រការចាំបាច់ដើម្បីបង្កើននូវកិច្ចការពារដ៏មានប្រសិទ្ធភាពទល់នឹងករណីរំលោភបំពានសិទ្ធិរបស់ពួកគេ។

ការបង្ហាញពីភាពគ្មានសិទ្ធិអំណាចដែលអ្នកភូមិនៅតាមទីជនបទតើបប្រទះ នៅពេលតទល់ជាមួយនឹងការប្រឈមលើបញ្ហាដីធ្លីរបស់ពួកគេនោះគឺករណីរបស់គ្រួសារទាំង៣៨មកពីភូមិបួនក្នុងខេត្តបាត់ដំបង ដែលបានជាប់ពាក់ព័ន្ធនឹងការប្តឹងផ្តល់គ្នាក្នុងតុលាការអស់រយៈពេល១២ឆ្នាំ ប្រឆាំងនឹងពាណិជ្ជករដ៏មានឥទ្ធិពលបីរូបជុំវិញករណីដីធ្លី ដែលអ្នកភូមិបានអះអាងថា ពួកគេបានធ្វើស្រែចម្ការចាប់តាំងពីអំឡុងឆ្នាំ១៩៩០-១៩៩២[12]មកម្លេះ ដែលរយៈពេលនេះលើសពី៥ឆ្នាំ តម្រូវដោយច្បាប់ភូមិបាលឆ្នាំ២០០១ ដែលផ្តល់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់ពួកគាត់សម្រាប់ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។[13] ដោយពុំមានប្រាក់ជិះរថយន្ត អ្នកភូមិរួមគ្នាជាមួយកសិករមកពីភូមិជិតខាងគ្នាធ្វើដំណើរថ្មើរជើងឆ្ពោះទៅកាន់រាជធានីភ្នំពេញកាលពីឆ្នាំ២០០៨ ដើម្បីស្វែងរកជំនួយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សូមឲ្យលោកនាយករដ្ឋមន្ត្រីជួយដោះស្រាយវិវាទរបស់ពួកគេ។ នគរបាលបានវាយទៅលើអ្នកភូមិជាច្រើន និងបានប្រាប់អ្នកភូមិឲ្យត្រឡប់ទៅផ្ទះវិញ ប៉ុន្តែពួកអ្នកភូមិនៅតែបន្តដំណើរ និងបានមកដល់របងភូមិគ្រឹះរបស់លោកនាយករដ្ឋមន្ត្រី។ បន្ទាប់មកត្រូវបានសន្យាជួយអន្តរាគមន៍ពីសំណាក់ រ.រ.ក ក្នុងវិវាទរបស់ពួកគេ ប្រសិនបើពួកគេត្រឡប់ទៅផ្ទះវិញ ពួកគាត់បានត្រឡប់ទៅវិញ ប៉ុន្តែគ្មានការជួយពីសំណាក់រដ្ឋាភិបាលនោះទេ។

## ការចុះបញ្ជី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីមិនគ្រប់គ្រាន់

យោងតាមច្បាប់នាពេលបច្ចុប្បន្ននេះ កម្មសិទ្ធិលើដីឯកជនអាចធ្វើបានតាមច្រើនរបៀប ប៉ុន្តែតាមវិធានជាទូទៅ ភាពរឹងមាំនៃប័ណ្ណកម្មសិទ្ធិដីធ្លីគឺពាក់ព័ន្ធជាមួយនឹងកម្រិតនៃរដ្ឋាភិបាលដែលចេញប្លង់នោះ។ ប្លង់ទន់ ដែលគេស្គាល់ថាជា"ប័ណ្ណកាន់កាប់ដីធ្លី" ដែលបញ្ជាក់ត្រឹមតែសិទ្ធិ"កាន់កាប់"ហើយមិនមែនមាន "ឋានៈជាម្ចាស់កម្មសិទ្ធិ" ត្រូវចុះបញ្ជីជាមួយអាជ្ញាធរថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាល ហើយមិនត្រូវបានកត់ត្រាទុកជាមួយនឹងបញ្ជីរបស់ រ.រ.ក ដូចជានៅថ្នាក់ជាតិនោះឡើយ។ ប្លង់ទន់ងាយនឹងត្រូវបានបំពានតាមរយៈផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ដែលស្វែងរកដីធ្លី។ ម្យ៉ាងវិញទៀត ប្លង់រឹង គឺជាវិញ្ញាបនប័ត្របញ្ជាក់ពីកម្មសិទ្ធិ ដែលចេញដោយមន្ទីរសុរិយោដី ដែលជាភ្នាក់ងាររបស់ រ.រ.ក ព្រមទាំងបង្កើតបានជាសិទ្ធិកម្មសិទ្ធិពេញលេញលើដី។

ប្រទេសកម្ពុជា មិនត្រឹមតែខ្វះសមត្ថភាពគ្រប់គ្រងលើការចុះបញ្ជីប្លង់រឹងសម្រាប់ឲ្យម្ចាស់ដីអាចផ្តល់នូវឯកសារជាការចាំបាច់ប៉ុណ្ណោះទេ ប៉ុន្តែម្ចាស់ដីដែលអាចនឹងក្លាយជាកម្មសិទ្ធិករភាគច្រើនពុំមានឯកសារណាមួយដែលពួកគេត្រូវការដើម្បីអាចទទួលបានប្លង់រឹងទាំងនោះទេ ហើយភាគច្រើនពុំមានលទ្ធភាពក្នុងការចំណាយតម្លៃបន្ថែមលើការផ្ទេរដែលជាប់ពាក់ព័ន្ធក្នុងការទទួលបានប្លង់រឹង។[14] បន្ថែមលើបញ្ហាទាំងអស់នេះ គឺភាពគ្មានឆន្ទៈរបស់ រ.រ.ក ក្នុងការជួយប្រជាពលរដ្ឋខ្លួនក្នុងការចុះបញ្ជី និងរក្សាការពារដីធ្លីរបស់ប្រជាពលរដ្ឋ ដែលបានបង្ហាញពីការខកខាន

---

[12]គណៈកម្មការកិច្ចការសិទ្ធិមនុស្សកម្ពុជា 'បាត់បង់ដីៈ ការបណ្តេញចេញដោយបង្ខំ និងការគំរាមកំហែងក្នុងប្រទេសកម្ពុជា' (របាយការណ៍) (ខែកញ្ញា ឆ្នាំ២០០៩) អាចរកបានតាមៈ
www.chrac.org/eng/CHRAC%20Statement%20in%202009/Losing%20Ground%20FINAL.compressed.pdf

[13]

[14]ប្រកាសអន្តរក្រសួងស្តីពី ការកំណត់ពីប្រាក់ចំណូលបានមកពីថ្លៃសេវានៃសុរិយោដី លេខ.៣៧៧ សហវ(ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២) (កាត់)។

របស់រដ្ឋាភិបាលក្នុងការផ្តល់នូវព័ត៌មានពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ និងជំនួយដល់ប្រជាពលរដ្ឋ ហើយបែរជាធ្វើការជ្រៀតជ្រែកយ៉ាងសកម្មក្នុងកិច្ចប្រឹងប្រែងរបស់អ្នកដទៃក្នុងការធ្វើដូច្នោះទៅវិញ។

ឧបសគ្គក្នុងការទទួលបានប្លង់រឹងទាំងនេះ បណ្តាលឲ្យជួបកាន់តែពិបាកខ្លាំងឡើងក្នុងការចិញ្ចឹមជីវិតដោយថាពលរដ្ឋខ្មែរម្នាក់ពុំមានប័ណ្ណកាន់កាប់ដីធ្លីរបស់ខ្លួនទាល់តែសោះវាទំនងជាគ្មានឱកាសទទួលបានប្លង់ទន់ទៀតផង ហើយជាលទ្ធផលគឺថាជាចេតនារបស់អាជ្ញាធរកម្ពុជា ដើម្បីផ្តល់ ដី.ស.ស ទៅឲ្យអ្នកចង់បានដែលមានឥទ្ធិពលជាងអ្នកកាន់កាប់ដីធ្លីនាពេលបច្ចុប្បន្ននេះ។

រ.រ.ក ពុំមានលទ្ធភាពគ្រប់គ្រាន់ផ្នែករដ្ឋបាលក្នុងការកត់ត្រា និងបង្កើតបញ្ជីកម្មសិទ្ធិលើដីធ្លីដែលសាធារណៈជនអាចរកបាន។ នៅពេលដែល រ.រ.ក បានអនុញ្ញាតឲ្យមានជាលើកដំបូងចំពោះការចែក និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី មានពាក្យស្នើសុំចុះបញ្ជីដំបូងចំនួន៤,៥ លាន[15] ត្រូវបានទទួលដោយមន្ត្រីចុះបញ្ជីដីធ្លី។ ដោយមានជំនាញ និងធនធានតិចតួច ឬក៏ប្រព័ន្ធមួយដែលអាចដំណើរការទៅបានសម្រាប់ការរ៉ាប់រងដ៏ធំធេងបែបនេះ ការិយាល័យចុះបញ្ជីបានក្លាយជាកន្លែងកកស្ទះ និងពុំមានដំណើរការប្រកបដោយប្រសិទ្ធភាពភ្លាមៗតែម្តង។ បន្ថែមពីលើអសមត្ថភាពនៃការគ្រប់គ្រងរបស់ រ.រ.ក ចំពោះដំណើរការចុះបញ្ជីប័ណ្ណដីធ្លីត្រឹមត្រូវដែលជាការចាំបាច់ ភាគតិចនៃការចុះបញ្ជីដីធ្លីដែលមានពុំត្រូវបានដាក់ឲ្យសាធារណៈជនអាចរកបាននោះទេ។ នេះជាក្តីព្រួយបារម្ភដ៏ក្រៃលែងមួយ ពីព្រោះប្លង់ទន់ដែលបញ្ជាក់ពីសិទ្ធិនៃការកាន់កាប់លើដីធ្លីមិនត្រូវបានគេចុះបញ្ជីនៅថ្នាក់ជាតិនោះទេ ដែកខុសស្រឡះនឹងប្លង់រឹងដែលបញ្ជាក់ពីកម្មសិទ្ធិស្របច្បាប់ពេញលក្ខណៈ។ នៅខណៈដែលធនាគារពិភពលោក ក្នុងភាពជាដៃគូជាមួយប្រទេសជ្រើសរើសនានា បានធ្វើការសហការជាមួយនឹង រ.រ.ក ចាប់តាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៩ ដើម្បីអភិវឌ្ឍនូវប្រព័ន្ធចុះបញ្ជីដីធ្លីបែបទំនើប ("គ.រ.គ.ដ")[16] គម្រោងនេះពុំមានលទ្ធភាពអនុវត្តទៅបានដោយជោគជ័យនូវគោលដៅក្នុងការចុះបញ្ជី និងការរក្សាគល់បញ្ជី ដែលខ្លួនបានកំណត់តាំងពីដំបូង។[17]

នៅក្នុងឆ្នាំ២០១០ មានត្រឹមតែចំនួន២២%ប៉ុណ្ណោះក្នុងចំណោមវិវាទដីធ្លីទាំងអស់ ក្នុងប្រទេសកម្ពុជាដែលបានឆ្លងកាត់តាមរយៈដំណើរការដោះស្រាយវិវាទ ត្រូវបានដោះស្រាយដោយផ្នែក ឬទាំងស្រុង។[18] នេះគឺជាបញ្ហាដោយផ្នែក ដោយសារតែគ្រប់គ្រងនូវមានភាពទន់ខ្សោយលើកម្មវិធីវាស់វែងដីធ្លីរបស់ រ.រ.ក។ មន្ត្រីរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ មិនត្រឹមតែមានអាណត្តិជាកំណត់ក្នុងការដោះស្រាយវិវាទដីធ្លីឲ្យបានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែត្រូវគេដាក់បន្ទុកបន្ថែមទៀតតាមរយៈឧបសគ្គការិយាធិបតេយ្យ ហើយជាញឹកញាប់ណាស់មន្ត្រីទាំងនោះមានរបៀបវារៈដោយខ្លួនឯងដើម្បីធ្វើកិច្ចការនោះ។

---

[15]មីកា-ប៉េទេរី តំរហូនែន ' ការធ្វើឲ្យប្រសើរឡើងក្នុងការរៀបចំដីធ្លីក្នុងប្រទេសកម្ពុជា( ឆ្នាំ២០០១ ) ២៥.៤ កុំព្យូទ័រ បរិស្ថាន និងប្រព័ន្ធនានានៃទីក្រុង ៤០៧,៤១០

[16]ធនាគារពិភពលោក គម្រោងរៀបចំ និងគ្រប់គ្រងដីធ្លី អាចរកបានតាម៖www.worldbank.org/projects/P070875/land-management-administration-project?lang=en

[17]ធនាគារពិភពលោក ‵ សេចក្តីថ្លែងការណ៍ពីធានាគារពិភពលោក ស្តីពីការបញ្ចប់ដោយរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងគ្រប់គ្រង និងរៀបចំដីធ្លី′ (ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៩ ) អាចរកបានតាម៖http://go.worldbank.org/TFCTB1QZK0

[18]វេទិការបស់អង្គការមិនមែនរដ្ឋាភិបាល ‵ កិច្ចវិភាគផ្នែកស្ថិតិស្តីពីជម្លោះដីធ្លីក្នុងប្រទេសកម្ពុជា ឆ្នាំ២០១០′ (មិថុនា ឆ្នាំ២០១១ )អាចរកបានតាម៖www.ngoforum.org.kh/docs/publications/LIP_Final_Land%20dispute%20report%202010_English.pdf

ក្នុងឆ្នាំ២០១២ បើទោះជាមានលិខិតមួយដែលចេញដោយ រ.រ.ក និងត្រូវបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការផ្តល់ដីទំហំ៥៥៨ហិកតា ជូនដល់ប្រជាពលរដ្ឋចំនួន៤១៥គ្រួសារ នៅភូមិ ស្ថិតនៅក្នុងខេត្តបាត់ដំបងយ៉ាងណាក្តី និស្សិតស្ម័គ្រចិត្តដែលគេចាត់ឲ្យទៅវាស់វែងដីបានអនុវត្តបទបញ្ជា ប្រឆាំងគ្នាពីសំណាក់អាជ្ញាធរ ដែលបង្គាប់ពួកគេកុំឲ្យយកចិត្តទុកដាក់ចំពោះលិខិតផ្តល់ដីនោះ ហើយវាស់វែងដីដែលមានទំហំតិចជាង៥០០ហិកតា ព្រមទាំងទុកដីដែលនៅសល់ឲ្យក្រុមហ៊ុនសាជីវកម្ម។[19] និស្សិតស្ម័គ្រចិត្តទាំងនេះ ដែលជាផ្នែកមួយនៃកម្មវិធីដ៏ធំរបស់រដ្ឋាភិបាល ក្នុងការវាស់វែងព្រំប្រទល់ដី ត្រូវបានផ្តល់ការបណ្តុះបណ្តាលរយៈពេលត្រឹមតែពីរថ្ងៃមុន ដែលខ្វះសិទ្ធិសម្រេច និងខ្វះបទពិសោធដើម្បីបំពេញកិច្ចការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហើយគ្រាន់តែជាឧបករណ៍ សម្រាប់ឲ្យតំណាងរដ្ឋាភិបាលណាម្នាក់ប្រាប់ពួកគេឲ្យធ្វើតាមតែប៉ុណ្ណោះ។

**ការគំរាមកំហែង និងការបំភិតបំភ័យពីសំណាក់ រ.រ.ក និងជនមានទំនាក់ទំនងស្និទ្ធ**

រ.រ.ក ជាញឹកញាប់ប្រើប្រាស់ការបំភិតបំភ័យ និងអំពើហិង្សាខាងរាងកាយលើប្រជាពលរដ្ឋខ្លួនឯង ដើម្បីបណ្តេញពួកគេចេញពីដីធ្លី ជាជាងផ្តល់នូវដំណើរការមួយប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដែលការតវ៉ាជំទាស់របស់ពួកគេអាចត្រូវបានដោះស្រាយយ៉ាងយុត្តិធម៌។ ឧទាហរណ៍ កាលពីខែមេសា ឆ្នាំ២០០៧ ទាហ៊ានប្រដាប់ដោយអាវុធ នគរបាលក្រុង និងនគរបាលស្លៀកឯកសណ្ឋានស៊ីវិលប្រមាណជា១៥០នាក់បានបញ្ជាឲ្យពលរដ្ឋរស់នៅក្នុងស្រុកមិត្តភាព ខេត្តព្រះសីហនុ ចាកចេញពីផ្ទះ និងដីរបស់ពួកគេជាបន្ទាន់។ បន្ទាប់ពីអ្នកភូមិបដិសេធមិនព្រមអនុវត្តតាមបទបញ្ជានោះ នគរបាលដោយមានការប្រើប្រាស់កាំភ្លើង ដំបង ដំបងឆក់ ឧស្ម័នបង្ហូរទឹកភ្នែក និងកាំភ្លើងបាញ់ទឹក បានបណ្តេញអ្នកភូមិចេញដោយបង្ខំ។ អ្នកភូមិត្រូវបាននគរបាលវាយដំ និងផ្ទះរបស់ពួកគេបានត្រូវដុតកម្ទេចចោល នាពេលនោះ ពួកគេត្រូវគេប្តូរទីកន្លែងចេញពីដីដែលដើមឡើយជាដីដាំដុះ និងជាដីធ្វើកសិកម្មដោយសហគមន៍របស់ពួកគេចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៨០មកម្លេះ ដែលមុនមានសេចក្តីតម្រូវនៃការតាំងលំនៅដ្ឋានរយៈពេល៥ឆ្នាំតាមច្បាប់ភូមិបាលឆ្នាំ២០០១ បានអនុវត្តទៅទៀត។ ពួកគេពុំមានលទ្ធភាពប្រជែងយក"សិទ្ធិ"កាន់កាប់ដីធ្លីពីសំណាក់ម្ចាស់ដែលបានទាមទារ ដែលត្រូវបានគូសបញ្ជាក់ដោយការិយាល័យសុរិយោដីមូលដ្ឋានថាជាភរិយារបស់ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី។[20]

ដោយមានកង្វះពីការធានារបស់រដ្ឋាភិបាលសម្រាប់កិច្ចការពារសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ អ្នកដែលស្ថិតក្នុងតួនាទីក្នុងការដកហូតដីធ្លី តាមរយៈការប្រើឥទ្ធិពលដកហូតដីធ្លីរបស់ពួកគេ ខណៈដែលកាលានុវត្តនេះនៅតែកើតមានឡើង។ នៅខែកុម្ភៈ ឆ្នាំ២០០៧ រ.រ.ក ដែលបានចូលរួមបង្ហាញនៃការដោះស្រាយបញ្ហាដោយខ្លួនឯងប្រកប

[19]ម៉ាយ ទិត្យធារ៉ា ' ជម្លោះដីធ្លីបង្វែរទៅតុលាការវិញ' កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២ អាចរកបានតាមៈ www.phnompenhpost.com/index.php/2012112059821/National-news/land-dispute-back-in-court.html

[20]លីកាដូ 'ការបង្ខំបណ្តេញ ដោយខុសច្បាប់លើគ្រួសារទាំង១០៥ ក្នុងខេត្តព្រះសីហនុ(សលាកប័ត្រពត៌មាន) (ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៧) អាចរកបានតាមៈwww.licadho-cambodia.org/reports/files/108LICADHOFactSheetIllegalEvictionSihanoukville07.pdf មជ្ឈមណ្ឌល ពីសិទ្ធិតាំងលំនៅដ្ឋាន និងការបណ្តេញចេញ,'កម្ពុជាៈ រឿងសំខាន់ស្តីពីការបណ្តេញចេញក្នុងខេត្តព្រះសីហនុ' (ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨) អាចរកបានតាមៈwww.cohre.org/news/press-releases/cambodia-feature-story-on-evictions-in-sihanoukville

ដោយតម្លាភាព បានយល់ព្រមជួលក្នុងរយៈពេល៩៩ឆ្នាំ នូវផ្ទៃដីមានទំហំ១៣៣ហិកតាទៅឲ្យក្រុមហ៊ុនស៊ូកាគូ[21] ដែលជាក្រុមហ៊ុនរបស់សមាជិកព្រឹទ្ធសភាខ្មែរដ៏មានឥទ្ធិពល ហើយដែលមានការជួយគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់ក្រុមហ៊ុនវិនិយោគចិន បានយល់ព្រមចំណាយទឹកប្រាក់សរុបដែលបានវាយតម្លៃយ៉ាងទាបប្រហែល៧៩លានដុល្លា សម្រាប់ដីនោះ ដើម្បីស្ថាបនានូវគម្រោងអភិវឌ្ឍន៍ដ៏ធំមួយ។ ក្រុមហ៊ុននេះ ត្រូវបានជ្រើសរើសឲ្យសាងសង់អចលនទ្រព្យផ្នែកពាណិជ្ជកម្ម និងលំនៅដ្ឋាននៅលើទីកន្លែងដែលធ្លាប់ជាបឹងដ៏ធំមួយក្នុងរាជធានីភ្នំពេញ តំបន់បឹងកក់ ដែលជាគេហដ្ឋានរបស់ប្រជាពលរដ្ឋជាង៤.០០០គ្រួសារ និងជាផ្នែកដ៏សំខាន់នៃទិដ្ឋភាពទីក្រុង និងប្រព័ន្ធលូបង្ហូរទឹក ឥឡូវគឺជាកន្លែងសម្រាប់កប់។ ជាច្រើនឆ្នាំមុន គឺនៅក្នុងឆ្នាំ២០០៤ ម្ចាស់ក្រុមហ៊ុន ភាពអ៊ីម៉ិច លីមីតធីត ដែលត្រូវជាភរិយារបស់សមាជិកព្រឹទ្ធិសភារូបនេះ បានត្រូវរដ្ឋាភិបាលប្រគល់ដីទំហំ៣១៥.០២៨ (ឬស្មើនឹង៧,៤%នៃផ្ទៃដីដាំដុះសរុបក្នុងប្រទេសកម្ពុជា)[22] ក្រោមរូបភាព ដី.ស.ស នៅក្នុងខេត្តចំនួនពីរ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

មានតែតាមរយៈសកម្មភាពជាបន្ទាន់ និងទូលំទូលាយពីសំណាក់ រ.រ.ក ដែលកំណែទម្រង់ដីធ្លីដែលត្រូវការយ៉ាងចាំបាច់អាចនឹងកើតមានឡើង ដើម្បីបំពេញតាមកាតព្វកិច្ចសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋរបស់ខ្លួនដោយអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ។

**<u>ដីសម្បទានសេដ្ឋកិច្ច៖</u>** ចំនួនកើនឡើងនៃការរំលោភបំពានសិទ្ធិមនុស្សជាច្រើនករណីកំពុងតែកើតមានឡើងនៅក្នុងបរិបទនៃដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានធ្វើឡើងដោយមិនគោរពឲ្យបានពេញលេញក្របខណ្ឌច្បាប់ ដែលគ្រប់គ្រងការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ ដូច្នេះ ម.ស.ម.ក ផ្តល់អនុសាសន៍ដូចខាងក្រោម៖

- **ការផ្អាកជាបណ្តោះអាសន្នដែលត្រូវបានប្រកាសឡើងដោយ រ.រ.ក កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចគួរតែត្រូវប្រតិបត្តិឲ្យបានតឹងរឹង ដរាបណា រដ្ឋាភិបាលបង្ហាញពីតម្លាភាពនៃអញ្ញត្រកម្មចំពោះការផ្អាកជាបណ្តោះអាសន្ននេះ ដែលអាចត្រូវបានគេធ្វើតាមរយៈការបោះពុម្ពផ្សាយនូវឈ្មោះរបស់អត្ថាគាហក និងទំហំដី ព្រមទាំងទីតាំងនៃដីសម្បទានសេដ្ឋកិច្ចទាំងនោះ ដែលពួកគេបានប្តេជ្ញាចិត្តតាំងពីដំបូង មុនពេលចូលជាធរមាននៃសេចក្តីប្រកាសផ្អាកនេះ។**
- **លក្ខណៈវិនិច្ឆ័យដែល រ.រ.ក ប្រើប្រាស់នៅក្នុងការពិនិត្យពិច័យ ដែលខ្លួនបានសន្យា គួរតែត្រូវបានផ្តល់ចំពោះ ដី.ស.ស ដែលបានប្រគល់ឲ្យហើយមុនពេលមានការផ្អាក គួរតែត្រូវធ្វើឲ្យគេអាចរកបានជាសាធារណៈ។**
- **ប្រកាន់ខ្ជាប់ចំពោះការកំណត់នៃទំហំផ្ទៃដី១០.០០០ ហិកតា ដែលត្រូវបានផ្តល់ឲ្យទៅកម្មសិទ្ធិករណាម្នាក់ លើអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មគួរតែត្រូវអនុវត្តឲ្យបានតឹងរឹង។**
- **ប្រកាន់ខ្ជាប់ចំពោះសេចក្តីតម្រូវដែលការវាយតម្លៃពីផលប៉ះពាល់ដល់សង្គម និងផ្នែកបរិស្ថាន ត្រូវបានបង្កើតក្នុងការវាយតម្លៃ និងការផ្តល់នូវ ដី.ស.ស ណាមួយគួរតែត្រូវអនុវត្តឲ្យបានហ្មត់ចត់។**

---

[21]មសមក ' ករណីសិក្សា៖ បឹងកក់' (សលាកប័ត្រពត៌មាន)(ឆ្នាំ២០១១) អាចរកបានតាម៖ www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=17&id=5

[22]អង្គការ គ្លូបលវីដណេស 'ប្រទេសសម្រាប់លក់'(របាយការណ៍) អាចរកបានតាម៖www.globalwitness.org/library/country-sale

- រាល់ ដី.ស.ស ទាំងអស់ដែលបានធ្វើសម្បទានបន្ទាប់ពីការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ គួរតែត្រូវពិនិត្យពិច័យ ដើម្បីកំណត់ថាតើត្រូវបានធ្វើឡើងដោយមានការរំលោភលើការកំណត់ទំហំផ្ទៃដី១០.០០០ហិកតាចំពោះកម្មសិទ្ធិករម្នាក់សម្រាប់អត្ថប្រយោជន៍ពាណិជ្ជកម្មឬទេ និងការពិនិត្យមើលឡើងវិញ ដែលបានធ្វើសម្រាប់ការវាយតម្លៃពីផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន ដែលត្រូវបានគេធ្វើមុនពេលមានការផ្តល់ ដី.ស.ស ទាំងនោះ ហើយប្រសិនបើ ដី.ស.ស ដែលបានផ្តល់ឲ្យហើយនោះរំលោភលើការធានាទាំងនេះ គួរតែត្រូវធ្វើការដកហូតយកមកវិញ ព្រមទាំងការខូតខាតដែលបានវាយតម្លៃប្រឆាំងនឹងអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មដែលបានមកដោយការបំពាន។

<u>**ដោះស្រាយបញ្ហានៃការបណ្តេញចេញដោយបង្ខំ៖**</u> ការបណ្តេញចេញដោយបង្ខំធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍ និងស្ថិរភាពសេដ្ឋកិច្ច ដោយសារតែប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញ ជាញឹកញាប់ត្រូវបានដកហូតនូវជីវភាពនៃការចិញ្ចឹមជីវិត និងត្រូវបានតាំងទីលំនៅដ្ឋានថ្មីនៅកន្លែង ដែលពុំបានប្រតិបត្តិតាមបទដ្ឋានអន្តរជាតិ។ ដោយហេតុដូច្នេះ ម.ស.ម.ក ផ្តល់អនុសាសន៍ដូចខាងក្រោម៖

- អនុវត្តគោលការណ៍នៃការផ្អាកជាបណ្តោះអាសន្នជាបន្ទាន់ ចំពោះករណីនៃការបណ្តេញចេញដោយបង្ខំនានា។
- ដោះលែងជាបន្ទាន់ និងទម្លាក់ចោលរាល់ការចោទប្រកាន់ប្រឆាំងនឹងបុគ្គលដែលបានតវ៉ាដោយអហិង្សា ក្នុងកិច្ចការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ។
- បង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យ និងមានតុល្យភាព ដែលថាមានតែបុគ្គលជាក់លាក់មួយចំនួនដែលទទួលខុសត្រូវសម្រាប់សកម្មភាពនានាតែប៉ុណ្ណោះមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងការបណ្តេញចេញដោយបង្ខំបានឲ្យ។

<u>**ការវាស់វែង ការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី៖**</u> ប្រសិនបើកម្មវិធីវាស់វែង និងផ្តល់ប្លង់កម្មសិទ្ធិរបស់ រ.រ.ក នឹងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនោះ ដំណើរការរបស់កម្មវិធីនេះ ត្រូវតែពាក់ព័ន្ធជាមួយនឹងបុគ្គលដែលត្រូវបានបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីបំពេញការងារ និងដែលត្រូវបានផ្តល់សិទ្ធិអំណាចឲ្យដើម្បីធ្វើសេចក្តីសម្រេចនានាដោយមានទិន្នន័យនៃគ្រប់ភាគីទាំងអស់ដែលមានផលប្រយោជន៍នៅលើដី។ ដូច្នេះហើយ ម.ស.ម.ក ផ្តល់អនុសាសន៍ដូចខាងក្រោម៖

- ការប្រើប្រាស់និស្សិតស្ម័គ្រចិត្តត្រូវតែបញ្ឈប់ជាបន្ទាន់ ហើយជាក់ជំនួសមកវិញដោយអ្នកវាស់វែងដែលមានបទពិសោធន៍ និងមានការបណ្តុះបណ្តាលត្រឹមត្រូវ។
- ប្រសិនបើគ្មានឯកសារជាក់លាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដើម្បីបញ្ជាក់ពីព្រំប្រទល់ដីដែលត្រូវធ្វើការវាស់វែងទេ ដីនោះពុំគប្បីត្រូវធ្វើការវាស់វែងឡើយ លុះត្រាតែឯកសារចាំបាច់នោះអាចទទួលបាន។
- ប្រសិនបើបុគ្គលណាត្រូវបានចាត់ឲ្យវាស់វែងព្រំប្រទល់ដី ពុំមានឯកសារបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលបង្ហាញពីអ្វីដែលនឹងត្រូវធ្វើការវាស់វែងទេនោះ ការកំណត់ព្រំប្រទល់ពិតប្រាកដអាចធ្វើឡើងរួមគ្នាដោយមានទិន្នន័យពីភាគីពាក់ព័ន្ធទាំងអស់ ប៉ុន្តែប្រសិនបើបុគ្គលណាម្នាក់មិនយល់ព្រមទៅនឹង

ការវាយតម្លៃពីព្រំប្រទល់ដីនោះទេ ដំណើការប្តឹងតវ៉ាដ៏មានតម្លាភាពគួរតែអនុវត្ត និងអាចស្វែងរកបានសម្រាប់ភាគីរងគ្រោះដើម្បីស្វែងរកយុត្តិធម៌។

- បុគ្គលទាំងឡាយណាដែលទទួលបានការវាស់វែងដីរួចរាល់ហើយ ឬក៏ទើបតែបានបញ្ជាក់នៅពេលថ្មីៗនាពេលបច្ចុប្បន្ននេះ ដែលរស់នៅលើដីដែលមិនទាន់បានកំណត់ថាជាដីរដ្ឋ ឬក៏មិនមែនជាដីមានវិវាទ នឹងត្រូវ*ចាត់ទុក*ថាជាការកាន់កាប់ស្របច្បាប់នៅលើដីនោះ ហើយនឹងត្រូវអាជ្ញាធរចេញប្លង់ដំបូងឲ្យ ដែលនឹងត្រូវទទួលបានប្លង់រឹងអចិន្ត្រៃយ៍ជា*ស្វ័យប្រវត្តិ* ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការអាស្រ័យ ផលនៅលើដីនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងមានការផ្តល់ឲ្យបុគ្គលផ្សេងទៀតដើម្បីដាក់ពាក្យប្តឹងជំទាស់ និងធ្វើការវិនិច្ឆ័យប្រកបដោយតម្លាភាព ហើយនៅពេលប្លង់រឹងបានត្រូវគេចេញឲ្យហើយ ប្លង់នោះនឹងត្រូវបានគេចុះបញ្ជីទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ហើយគល់បញ្ជីនោះ គួរនឹងត្រូវធ្វើឡើងជាមួយនឹងតតិយជន ដែលអ្នកថែរក្សាបញ្ជីនេះនឹងបង្ហាញគល់បញ្ជីទាំងនោះដែលអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិចទៅកាន់សាធារណៈជនទូទៅ។
- ដើម្បីកំណត់នូវការប៉ាន់ស្មានអំពីដីធ្លី ការផ្អាកជាបន្ទាន់ចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិទៅឲ្យអ្នកដែលមានផលប្រយោជន៍ពាណិជ្ជកម្មណាមួយនោះគួរតែត្រូវបង្កើតឡើង ដោយបម្រាមដូចគ្នានេះ ក៏អនុវត្តចំពោះបុគ្គលណាដែលធ្វើការទាមទារលើដីដែលពួកគេពុំទាន់បានបង្កើតសិទ្ធិកាន់កាប់លំនៅដ្ឋាន ហើយបន្ថែមលើនេះទៀត គ្មានការផ្តល់ប្លង់កម្មសិទ្ធិលើដីបន្ថែមទៀតគួរត្រូវបានអនុញ្ញាតសម្រាប់ទំហំដីច្រើនកន្លែងទៅឲ្យបុគ្គលណាម្នាក់នោះឡើយ ។
- ការផ្អាកជាបណ្តោះអាសន្នគួររក្សាឲ្យនៅអនុវត្ត រហូតដល់ដំណើរការមួយត្រូវបានបង្កើតឡើង ដែលបុគ្គលនានាធ្វើការទាមទារប្លង់លើទ្រព្យសម្បត្តិពាណិជ្ជកម្ម និងអចលនទ្រព្យជាលំនៅដ្ឋានដ៏ច្រើន តម្រូវឲ្យចំណាយតម្លៃតាមផ្លូវច្បាប់ដែលមានឯករាជ្យសម្រាប់ជនទាំងឡាយណាដែលដីរបស់ពួកគេប្រឈមនឹងការរឹបអូសយក ប្រសិនបើ អ្នកទាមទារគឺជាមន្ត្រីរដ្ឋាភិបាល ឬសាច់ញាតិរបស់ពួកគេ ពួកគេត្រូវតែស្ថិតក្រោមប្រព័ន្ធនៃការត្រួតពិនិត្យដែលមានកម្រិតខ្ពស់ ដែលមានតម្លាភាពក្នុងការបំពេញមុខងាររបស់ខ្លួន ហើយអាចនាំឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ប្រសិនបើប្រព្រឹត្តទៅដោយមានអំពើទុច្ចរិត។
- ការទាមទារដីលំនៅដ្ឋាន គួរតែ*ចាត់ទុក*ថាជារឿងសំខាន់ជាងអ្នកទាំងឡាយណាដែលធ្វើសម្រាប់ ផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ប្រសិនជាមានវិវាទចំពោះសិទ្ធិដីធ្លី ហើយពុំមានដីណាដែលអ្នកភូមិតាំងទីលំនីនាពេលបច្ចុប្បន្ន និង/ឬ លើដីដែលពួកគេធ្លាប់តែបង្កបង្កើនផលកសិកម្មនឹងត្រូវផ្តល់ទៅឲ្យអ្នកដែលមានផលប្រយោជន៍ពាណិជ្ជកម្ម ដោយពុំមានការអនុវត្តន៍នូវការធានាផ្នែកច្បាប់យ៉ាងតឹងរឹងនោះទេ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥(០)១២ ៤០ ៤០ ៥១ ឬអ៊ីម៉េល ouvirak@cchrcambodia.orgឬលោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមរយៈទូរសព្ទ +៨៥៥ (០)៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉េល robert.finch@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
cc BY NC SA